ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## (គ.ជ.អ.ប.)

# របាយការណ៍

# ស្តីពី

# ទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៉ុញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម អំពីការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ខេត្តប៉ុញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ថ្ងៃទី១៦-១៩ ខែវិច្ឆិកា ឆ្នាំ២០២៣

## មាតិកាចាយការណ៍


I. សេចក្តីផ្តើម ........ 1

១. គោលបំណង ........ 2

២. សមាសភាពគណៈប្រតិភូកម្ពុជា ........ 2

៣. កម្មវិធីទស្សនកិច្ចសិក្សា ........ 3

II. លទ្ធផលនៃទស្សនកិច្ចសិក្សា និងការសិក្សាស្រាវជ្រាវ ........ 4

ក. អំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសវៀតណាម ........ 4

ក.១. អំពីក្រុមប្រឹក្សាប្រជាជនខេត្ត ........ 5

ក.២. អំពីគណៈកម្មាធិការប្រជាជនខេត្ត ........ 7

ក.៣. មុខងាររបស់រដ្ឋបាលខេត្ត ........ 8

ក.៤. តួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត ........ 8

ក.៥. តួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ........ 9

ក.៦. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ........ 10

ខ. អំពីរដ្ឋបាលខេត្តប៊ិញយឿង ........ 11

គ. ការរៀបចំប្រព័ន្ធអប់រំនៅប្រទេសវៀតណាម ........ 12

ឃ. ការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសវៀតណាម ........ 13

ឃ.១. ការរៀបចំកម្មវិធីសិក្សា ........ 13

ឃ.២. ការជ្រើសរើសគ្រូបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀន ........ 13

ឃ.៣. យន្តការគ្រប់គ្រងសាលា ........ 14

ឃ.៤. ការតែងតាំងនាយកសាលា ........ 14

ឃ.៥. ការរៀបចំកម្មវិធីអាហារថ្ងៃត្រង់សម្រាប់ការអប់រំកុមារតូច ........ 14

ឃ.៦. យន្តការគាំទ្រ និងតាមដាន ត្រួតពិនិត្យ ........ 14

ឃ.៧. ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាព ........ 14

III. មេរៀន បទពិសោធន៍នៃការអនុវត្តមុខងារអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រទេសវៀតណាម ........ 15

IV. កម្មវិធីផ្សេងៗ ........ 16

V. សេចក្តីសន្និដ្ឋាន ........ 17

## I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់វិមជ្ឈការក្នុងវិស័យអប់រំ យុវជន និងកីឡាជាជំហានៗ ដោយបានចាប់ផ្តើមផ្ទេរសិទ្ធិ អំណាច និងការទទួលខុសត្រូវលើការផ្តល់សេវាអប់រំមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤នៃខេត្តបាត់ដំបងនាឆ្នាំ២០១៩ សម្រាប់ជាការអនុវត្តសាកល្បង។ ផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃការអនុវត្តសាកល្បងនេះ នាឆ្នាំ២០២៣ រាជរដ្ឋាភិបាលក៏បានសម្រេចលើការពង្រីកការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាអប់រំបឋមសិក្សា មត្តេយ្យសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេសដែលត្រូវចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ២០២៤តទៅ តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ផ្អែកតាមស្មារតីនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដែលជាសេនាធិការឱ្យ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងគោលការណ៍ បែបបទ និងនីតិវិធីពាក់ព័ន្ធនានាសម្រាប់ផ្តល់ការណែនាំ និងបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រង ចាត់ចែង និងផ្តល់សេវាអប់រំដែលបានផ្ទេរឱ្យទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ស្របតាមស្តង់ដាសេវាអប់រំ។

ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តទាំងនេះ ចាំបាច់ត្រូវមានការសិក្សាស្រាវជ្រាវ និងដកស្រង់មេរៀន និងបទពិសោធន៍ល្អៗដែលធ្លាប់បានអនុវត្តនាពេលកន្លងមកនៅតាមរដ្ឋបាលក្រុង ស្រុកមួយចំនួនក្នុងប្រទេសកម្ពុជាផង និងមេរៀន និងបទពិសោធន៍ល្អៗដែលបាន និងកំពុងអនុវត្តនៅតាមបណ្តាប្រទេសនានាក្នុងតំបន់ផងដែរ។ ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានធ្វើការសិក្សាស្រាវជ្រាវលើឯកសារ និងប្រមូលព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមបណ្តាប្រទេសមួយចំនួនទាំងក្នុងតំបន់ផង និងអន្តរជាតិផង។ ក្នុងការសិក្សាស្រាវជ្រាវនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានរកឃើញថា សាធារណរដ្ឋសង្គមនិយមវៀតណាមគឺជាប្រទេសមួយដែលបានធ្វើវិមជ្ឈការក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយការធ្វើកំណែទម្រង់នេះបានធ្វើឱ្យគុណភាពនៃការផ្តល់សេវាអប់រំកាន់តែមានភាពល្អប្រសើរជាលំដាប់ ដែលទិន្នន័យចុងក្រោយរបស់ធនាគារពិភពលោកបានបង្ហាញថា បើគិតលើពិន្ទុសិក្សាសរុប សិស្សវៀតណាមមិនត្រឹមតែមានប្រៀបជាងសិស្សនៅក្នុងប្រទេសម៉ាឡេស៊ី និងថៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកម្រិតសមត្ថភាពលើសប្រទេសអង់គ្លេស និងកាណាដាដែលជាប្រទេសមានប្រាក់ចំណូលច្រើនជាងប្រទេសវៀតណាម។

អាស្រ័យហេតុនេះ ផ្អែកតាមគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** និងក្រោមការសម្របសម្រួល

ដោយ **ឯកឧត្តម វ៉ា ថន អភិបាលនៃគណៈអភិបាលខេត្តក្រចេះ** លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំគណៈប្រតិភូកម្ពុជា ដើម្បីធ្វើទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៊ិញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីសិក្សាស្វែងយល់អំពីការគ្រប់គ្រង និងផ្តល់សេវាអប់រំមត្តេយ្យសិក្សា និងបឋមសិក្សានៅថ្នាក់ក្រោមជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ដំណើរទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៊ិញយឿងនេះ ប្រព្រឹត្តទៅដោយមានគោលបំណង សមាសភាពប្រតិភូកម្ពុជា កម្មវិធី និងទទួលបានលទ្ធផលដូចខាងក្រោម៖

## ១. គោលបំណង

ទស្សនកិច្ចសិក្សានេះមានគោលបំណងសិក្សា ស្វែងយល់ និងដកស្រង់មេរៀន និងបទពិសោធន៍ល្អៗអំពីការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាអប់រំមត្តេយ្យសិក្សា និងការអប់រំបឋមសិក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីឆ្លុះបញ្ចាំង និងសម្រាប់ពិចារណាក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាអប់រំមត្តេយ្យសិក្សា និងបឋមសិក្សានៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។

## ២. សមាសភាពគណៈប្រតិភូកម្ពុជា

គណៈប្រតិភូកម្ពុជាដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសសំខាន់ៗនៃក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និងរដ្ឋបាលខេត្តក្រចេះដែលមានចំនួនសរុប ២៤រូប ដូចខាងក្រោម៖

| | |
|---|---|
| **១. ឯកឧត្តម ចាន់ សុធា** | **អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.** |
| **២. ឯកឧត្តម វ៉ា ថន** | **អភិបាលខេត្តក្រចេះ** |
| ៣. ឯកឧត្តម តូច ពលពន្លក | ទីប្រឹក្សាក្រសួងមហាផ្ទៃ |
| ៤. ឯកឧត្តម ចេង ម៉ានី | ទីប្រឹក្សាក្រសួងមហាផ្ទៃ |
| ៥. ឯកឧត្តម ហេង សុថា | អភិបាលរងខេត្តក្រចេះ |
| ៦. ឯកឧត្តម ជ័យ សម្បត្តិផល្លា | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ |
| ៧. ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា |
| ៨. ឯកឧត្តមបណ្ឌិត ចាន់ សុភា | ប្រធាននាយកដ្ឋានបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា |
| ៩. ឯកឧត្តមបណ្ឌិត ប្រាក់ កុសល | ប្រធាននាយកដ្ឋានអប់រំកុមារតូច ក្រសួងអប់រំ យុវជន និងកីឡា |
| ១០. ឯកឧត្តម បួន ហេង | ប្រធាននាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ |
| ១១. លោក លី យ៉ាសាក់ | ប្រធាននាយកដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ |
| ១២. លោកស្រី គង់ ប៊ុណ្ណា | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ |
| ១៣. លោក ប៊ុន ម៉ានិត | អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ |

១៤. លោក ហាន ដាលុយ អនុប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា
១៥. លោក ម៉ែន វណ្ណា នាយករដ្ឋបាល ខេត្តក្រចេះ
១៦. លោក ឡាយ បូរ៉ា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ
១៧. លោក លឹម សិរីវុឌ្ឍី ប្រធានការិយាល័យ ក្រសួងអប់រំ យុវជន និងកីឡា
១៨. លោក ចាន់ ប៉ូលីន ប្រធានការិយាល័យ លេខាធិការដ្ឋាន គ.ជ.អ.ប.
១៩. លោក ហែម សាមឿន ប្រធានការិយាល័យ លេខាធិការដ្ឋាន គ.ជ.អ.ប.
២០. លោក ពិសិដ្ឋ សិលា អនុប្រធានការិយាល័យ លេខាធិការដ្ឋាន គ.ជ.អ.ប.
២១. លោកឧត្តមសេនីយ៍ត្រី ម៉ៅ ធារី មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រចេះ
២២. លោក ឈា ផល្លី អភិបាលស្រុកអូរគ្រៀងសែនជ័យ ខេត្តក្រចេះ
២៣. លោក អ៊ឹម ពិសី អ្នកសម្របសម្រួលខេត្តក្រចេះ
២៤. លោក កែ វិបុល សមាជិកក្រុមប្រឹក្សាស្រុកអូរគ្រៀងសែនជ័យ។




### ៣. កម្មវិធីទស្សនកិច្ចសិក្សា

ទស្សនកិច្ចសិក្សានេះបានប្រព្រឹត្តទៅរយៈពេល០៣ថ្ងៃ **ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅខេត្តប៊ិញយឿង និងទីក្រុងហូជីមិញនៃប្រទេសវៀតណាម** ទៅតាមកម្មវិធីដូចខាងក្រោម៖

| ពេលវេលា | សកម្មភាព |
|---|---|
| ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣៖ ការចេញដំណើរពីរាជធានីភ្នំពេញទៅកាន់ខេត្តប៊ិញយឿង វៀតណាម | |
| **ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣** ខេត្តប៊ិញយឿង ប្រទេសវៀតណាម | |
| ៨:៣០-១០:00 | ទស្សនកិច្ចនៅគ្រឹះស្ថានផ្តល់សេវាអប់រំឯកជន Viet Anh (មត្តេយ្យដល់វិទ្យាល័យ) |
| ១០:00-១១:00 | ទស្សនកិច្ចនៅសាលាមត្តេយ្យសិក្សាសាធារណៈ Tuoi Ngoc |

| | |
|---|---|
| ១១:០០-១២:០០ | ការជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធនៃរដ្ឋបាលក្រុង**ធូយ៉ូវម៉ុក** ប្រទេសវៀតណាម |
| ១៤:០០-១៧:០០ | ការជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ មន្ទីរពាក់ព័ន្ធ និងថ្នាក់ដឹកនាំខេត្តប៊ិញយឿង |
| **ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣** ខេត្តប៊ិញយឿង និងទីក្រុងហូជីមិញ ប្រទេសវៀតណាម | |
| ៨:៣០-១០:០០ | ទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យ Eastern International University នៅខេត្តប៊ិញយឿង |
| ១៤:០០-១៧:០០ | ទស្សនកិច្ចនៅក្រុមហ៊ុន Thaco នៅទីក្រុងហូជីមិញ |
| **ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣** ខេត្តប៊ិញយឿង ប្រទេសវៀតណាម | |
| ១០:០០-១២:០០ | ទស្សនកិច្ចក្រុមហ៊ុនចំការកៅស៊ូដូវទៀង |
| បន្ទាប់ពីអាហារថ្ងៃត្រង់ គណៈប្រតិភូធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ។ | |

## II. លទ្ធផលនៃទស្សនកិច្ចសិក្សា និងការសិក្សាស្រាវជ្រាវ

### ក. អំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសវៀតណាម

រដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសវៀតណាមត្រូវបានបែងចែកជា ០៣ថ្នាក់ រួមមាន៖

- **ថ្នាក់ទី១៖** រដ្ឋបាលទីក្រុងធំ (មេត្រូប៉ូលីតែន) និងរដ្ឋបាលខេត្ត
- **ថ្នាក់ទី២៖** រដ្ឋបាលក្រុង ស្រុក (ស្រុកជនបទ, ស្រុកទីប្រជុំជន)
- **ថ្នាក់ទី៣៖** រដ្ឋបាលឃុំ សង្កាត់។

**រដ្ឋបាលទីក្រុងធំ** គឺជារដ្ឋបាលទីក្រុងមេត្រូប៉ូលីតែនដែលមានប្រព័ន្ធគ្រប់គ្រងដោយឡែកពីរដ្ឋបាលថ្នាក់ផ្សេងទៀត រួមមានទីក្រុងហូជីមិញ ទីក្រុងដាណាង ទីក្រុងហៃហ្វុង ទីក្រុងកាដូ និងទីក្រុងហាណូយ។

**ខេត្ត** ត្រូវបានបែងចែកជាក្រុង និងស្រុក (ស្រុកជនបទ Suburban, ស្រុកទីប្រជុំជន Urbandistrict) ដែលក្នុងនោះស្រុកត្រូវបានបែងចែកជាឃុំទីប្រជុំជន (Township) និងឃុំជនបទ (Commune) ហើយក្រុងត្រូវបែងចែកជាសង្កាត់ (ward) និងឃុំ។ បច្ចុប្បន្ននេះ ប្រទេសវៀតណាមមាន**ទីក្រុងធំចំនួន៥ ខេត្តចំនួន៥៨ ក្រុង ស្រុកចំនួន៧១៣ និងឃុំ សង្កាត់ចំនួន១១,១៦២។**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានដឹកនាំដោយក្រុមប្រឹក្សាប្រជាជន និងគណៈកម្មាធិការប្រជាជន ព្រមទាំងមានអនុគណៈកម្មាធិការមួយចំនួន និងមន្ទីរ/ការិយាល័យពាក់ព័ន្ធជាសេនាធិការ ដែលស្ថិតក្រោមការតម្រង់ទិសដោយគណៈកម្មាធិការបក្សកុម្មុយនិស្ត ហើយគណៈកម្មាធិការបក្សកុម្មុយនិស្តគឺជាស្ថាប័នដឹកនាំខ្ពស់បំផុតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាប្រជាជន គឺជាតំណាងនៃសំឡេងរបស់សហគមន៍នីមួយៗ ហើយត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយតំណាងប្រជាជននៅក្នុងមូលដ្ឋាននីមួយៗ។ ក្រុមប្រឹក្សាប្រជាជនជ្រើសរើសគណៈកម្មាធិការប្រជាជន។ គណៈកម្មាធិការប្រជាជនជាអង្គភាពប្រតិបត្តិមានតួនាទីគ្រប់គ្រង និងចាត់ចែងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយគណៈ

កម្មាធិការប្រជាជនដឹកនាំដោយប្រធាន ០១រូប និងមានអនុប្រធានយ៉ាងច្រើន ០៤រូប។ ក្រុមប្រឹក្សាប្រជាជន និងគណៈកម្មាធិការប្រជាជនត្រូវបានបង្កើតឡើងនៅគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ព្រមទាំងមានចំនួនផ្អែកទៅតាមតំបន់នីមួយៗ (ចំនួនប្រជាជន ភូមិសាស្ត្រ តំបន់ភ្នំ ។ល។) និងមានអាណត្តិការងាររយៈពេល ០៥ឆ្នាំ។

### ក.១. អំពីក្រុមប្រឹក្សាប្រជាជនខេត្ត

ក្រុមប្រឹក្សាប្រជាជនខេត្តមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

១- ក្នុងដំណើរការរៀបចំ និងធានាការអនុវត្តកិច្ចការនានាឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់៖

– ដោះស្រាយបញ្ហានានាដែលស្ថិតក្នុងតួនាទី និងអំណាចរបស់ក្រុមប្រឹក្សាប្រជាជន

– សម្រេចលើវិធានការនានា ដើម្បីរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ផ្សេងៗ ព្រមទាំងអំពើពុករលួយ

– សម្រេចលើវិធាននានាក្នុងគ្រប់គ្រងទ្រព្យសម្បត្តិ និងការពារអាយុជីវិតមនុស្ស សេរីភាព ទ្រព្យសម្បត្តិ សិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ

– សម្រេចលើវិធានការនានាក្នុងការអនុវត្តមុខងារដែលបានផ្ទេរដោយស្ថាប័នថ្នាក់ជាតិ ព្រមទាំងធ្វើវិមជ្ឈការតួនាទី និងអំណាចរបស់រដ្ឋបាលថ្នាក់ខេត្តទៅឱ្យរដ្ឋបាលមូលដ្ឋានថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ

– លុបចោលលិខិតបទដ្ឋានដែលពុំស្របច្បាប់ដែលបានដាក់ចេញដោយគណៈកម្មាធិការប្រជាជនថ្នាក់ខេត្ត ឬដែលចេញដោយក្រុមប្រឹក្សាប្រជាជនថ្នាក់ស្រុក

– លើកសំណើសុំរំសាយក្រុមប្រឹក្សាប្រជាជនថ្នាក់ស្រុក ប្រសិនបើក្រុមប្រឹក្សាប្រជាជននេះបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ប្រជាជន ព្រមទាំងសម្រេចលើការស្នើសុំរបស់ក្រុមប្រឹក្សាប្រជាជនថ្នាក់ស្រុកអំពីការរំសាយក្រុមប្រឹក្សាប្រជាជនថ្នាក់ឃុំ សង្កាត់។

២- ក្នុងដំណើរការរៀបចំការគ្រប់គ្រងរដ្ឋបាល៖

– ជ្រើសតាំង និងដកតំណែងប្រធាន អនុប្រធានក្រុមប្រឹក្សាប្រជាជន ប្រធាន អនុប្រធានគណៈកម្មាធិការប្រជាជនថ្នាក់ខេត្ត និងប្រធានការិយាល័យក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្ត

– បោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងមុខតំណែងនានាក្នុងខេត្ត

– បញ្ឈប់ក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តចេញពីតំណែង និងអនុម័តលើការលាលែងរបស់សមាជិកក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តចេញពីតំណែង

– ចេញសេចក្តីសម្រេចបង្កើត ឬលុបការបែងចែកភារកិច្ចនៃគណៈកម្មាធិការប្រជាជន

– សម្រេចលើការរៀបចំរចនាសម្ព័ន្ធមន្ត្រីរាជការដែលបម្រើការងារនៅអង្គភាពចំណុះក្រុមប្រឹក្សាប្រជាជន គណៈកម្មាធិការប្រជាជន និងអង្គភាពរដ្ឋបាលសាធារណៈ

– បង្កើត រំលាយ បញ្ចូលគ្នា និងបំបែកឃុំ និងសង្កាត់ ព្រមទាំងជ្រើសរើស ឬផ្លាស់ប្តូរឈ្មោះភូមិ ផ្លូវថ្នល់ ផ្លូវតូច និងរចនាសម្ព័ន្ធសាធារណៈ។

៣- វិស័យសេដ្ឋកិច្ច ធនធានធម្មជាតិ និងបរិស្ថាន៖

– រៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម រយៈពេលវែង រយៈពេលមធ្យម និងប្រចាំឆ្នាំ ព្រមទាំងសម្រេចផែនការ និងសំណើសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងវិស័យនានា

– ពិនិត្យ និងសម្រេចផែនការចំណូលរបស់រដ្ឋបាលខេត្ត រួមមានផែនការចំណូល និងចំណាយរបស់រដ្ឋបាលមូលដ្ឋាន និងការបែងចែកថវិកាតាមផែនការថវិកា

– កែសម្រួលផែនការថវិការបស់រដ្ឋបាលមូលដ្ឋាននៅពេលចាំបាច់ និងអនុម័តសមតុល្យថវិការបស់រដ្ឋបាលមូលដ្ឋាន ព្រមទាំងសម្រេចផែនការវិនិយោគ កម្មវិធី ឬគម្រោង

– សម្រេចលើថ្លៃសេវារដ្ឋបាល និងការទូទាត់ថ្លៃនានា

– សម្រេចលើផែនការ និងវិធានការជាក់លាក់ ដើម្បីលើកទឹកចិត្ត និងកៀរគរផ្នែកសេដ្ឋកិច្ចឱ្យចូលរួមក្នុងការផ្តល់សេវាសាធារណៈទូទាំងខេត្ត

– សម្រេចលើវិធានការផ្សេងៗ ដើម្បីកំណើនសេដ្ឋកិច្ច-សង្គមទូទាំងខេត្ត

– សម្រេចលើការសាងសង់ និងការធ្វើផែនការអភិវឌ្ឍន៍ទីក្រុង

– ធ្វើទំនាក់ទំនងផ្នែកសេដ្ឋកិច្ចក្នុងតំបន់រវាងរដ្ឋបាលមូលដ្ឋាននៅកម្រិតផ្សេងៗគ្នា ដើម្បីធានាឱ្យបាននូវស្ថិរភាពសេដ្ឋកិច្ចជាតិ

– សម្រេចលើការរៀបចំផែនការសម្រាប់ការអភិវឌ្ឍអង្គភាពផ្តល់សេវាកម្ម ដើម្បីពង្រីកវិស័យឧស្សាហកម្ម កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបណ្តាញពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងចរាចរណ៍ទូទាំងខេត្ត

– អនុម័តលើផែនការ និងសំណើប្រើប្រាស់ដីក្នុងខេត្ត មុននឹងស្នើសុំរដ្ឋាភិបាលផ្តល់ការយល់ព្រម និងសម្រេចវិធានការគ្រប់គ្រង ប្រើប្រាស់ធនធានដី ទឹក និងរ៉ែ និងប្រភពចំណូលដែលទទួលបានពីធនធានធម្មជាតិដទៃទៀត ព្រមទាំងការពារបរិស្ថាន។

៤- ការងារអប់រំ បណ្តុះបណ្តាល វិទ្យាសាស្ត្រ បច្ចេកវិទ្យា វប្បធម៌ ព័ត៌មាន កីឡា និងអប់រំកាយ៖

– សម្រេចលើវិធានការនានាក្នុងការអភិវឌ្ឍទីកន្លែង និងឧបករណ៍ផ្តល់សេវាអប់រំ និងលក្ខខណ្ឌនានា ដើម្បីធានាបាននូវប្រតិបត្តិការអប់រំ និងបណ្តុះបណ្តាល ព្រមទាំងកំណត់តម្លៃសេវាអប់រំ និងបណ្តុះបណ្តាលសាធារណៈ

– សម្រេចលើវិធានការដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍ ការស្រាវជ្រាវវិទ្យាសាស្ត្រ លើកកម្ពស់គំនិតច្នៃប្រឌិត ការកែលម្អបច្ចេកទេស ផ្នែកវិទ្យាសាស្ត្រ ឬបច្ចេកវិទ្យា

– សម្រេចលើវិធានការដើម្បីបង្កើនការអភិវឌ្ឍវប្បធម៌ ព័ត៌មាន អប់រំកាយ និងកីឡា។

៥- វិស័យថែទាំសុខភាព ការងារ និងការអនុវត្តគោលនយោបាយសង្គម៖

– សម្រេចលើវិធានការអភិវឌ្ឍន៍បណ្តាញគ្រឹះស្ថានថែទាំសុខភាពតាមខេត្ត ស្រុក និងឃុំ

– សម្រេចលើតម្លៃសេវាថែទាំសុខភាពដែលត្រូវអនុវត្តនៅគ្រឹះស្ថានថែទាំសុខភាពរដ្ឋ

– សម្រេចលើវិធានការការពារ ថែរក្សាសុខភាពប្រជាជន ការពារ និងមើលថែទាំកុមារ ចាស់ជរា ជនពិការ ជនក្រីក្រ និងកុមារកំព្រា ព្រមទាំងសម្រេចចិត្តលើវិធានការបង្ការ និងគ្រប់គ្រងជំងឺរាតត្បាត វិធានការអនុវត្តគោលនយោបាយស្តីពីចំនួនប្រជាជន និងផែនការគ្រួសារ

– សម្រេចលើវិធានការគ្រប់គ្រង ប្រើប្រាស់ និងអភិវឌ្ឍធនធានមនុស្សក្នុងខេត្ត រួមទាំងវិធានការបង្កើតការងារ បង្កើនផលិតភាព បង្កើនប្រាក់ចំណូល និងកែលម្អលក្ខខណ្ឌការងារ និងធានាសុវត្ថិភាពការងារ និងអនាម័យ

– សម្រេចលើគោលនយោបាយលើកទឹកចិត្តដល់មន្ត្រីរាជការ បុគ្គលិកសាធារណៈ និងកម្មករ និយោជិតឱ្យទៅធ្វើការនៅតាមខេត្ត ដែលពាក់ព័ន្ធទៅនឹងសមត្ថភាពថវិការបស់រដ្ឋបាលមូលដ្ឋាន និងគោរពតាមបទប្បញ្ញត្តិដែលដាក់ចេញដោយស្ថាប័នថ្នាក់លើ។

៦- កិច្ចការជនជាតិភាគតិច និងសាសនា៖

– សម្រេចលើវិធានការអនុវត្តគោលនយោបាយជនជាតិភាគតិច កែលម្អជីវភាព និងលើកកម្ពស់ស្តង់ដាបញ្ញារបស់ជនជាតិភាគតិច និងធានាសមភាពពូជសាសន៍

– សម្រេច និងកំណត់លើវិធានការ ដើម្បីអនុវត្តគោលនយោបាយសាសនា វិធានការធានាសមភាពសាសនា ជំនឿ និងសេរីភាពខាងសាសនា។

៧- វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម៖

– សម្រេចលើវិធានការក្នុងការធានាការអនុវត្តភារកិច្ចការពារជាតិ និងសន្តិសុខ ស្របតាមច្បាប់ ព្រមទាំងលើកកម្ពស់សន្តិសុខនយោបាយ ប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងគ្រប់គ្រងឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ផ្សេងៗ ព្រមទាំងធានាសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម

– សម្រេចលើផែនការ និងវិធានការនានា ដើម្បីអភិវឌ្ឍសក្តានុពលក្នុងមូលដ្ឋាន កសាងកម្លាំងការពារជាតិ និងសន្តិសុខរបស់ប្រជាជនទាំងអស់

– សម្រេចលើផែនការ និងវិធានការកសាងកងកម្លាំងការពារ ស្វ័យការពារ កងជីវពល កម្លាំងបម្រុង នគរបាលឃុំតាមមូលដ្ឋាន

– សម្រេចលើវិធានការក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពចរាចរណ៍។

៨- ក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តត្រូវបំពេញភារកិច្ច និងអនុវត្តអំណាចរបស់ខ្លួនក្នុងការត្រួតពិនិត្យការអនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ក្នុងខេត្ត ការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដោយត្រួតពិនិត្យប្រតិបត្តិការរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាប្រជាជន គណៈកម្មាធិការប្រជាជន តុលាការប្រជាជន ធ្វើលទ្ធកម្មក្រុមប្រឹក្សាប្រជាជន និងគណៈកម្មាធិការនៃក្រុមប្រឹក្សាប្រជាជនថ្នាក់ក្រោម ព្រមទាំងត្រួតពិនិត្យលិខិតបទដ្ឋានរបស់គណៈកម្មាធិការប្រជាជន និងក្រុមប្រឹក្សាប្រជាជនថ្នាក់ក្រោម។

៩- ក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តបំពេញតួនាទី និងការទទួលខុសត្រូវផ្សេងទៀត។

### ក.២. អំពីគណៈកម្មាធិការប្រជាជនខេត្ត

គណៈកម្មាធិការប្រជាជនខេត្តមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

១. រៀបចំ និងដាក់ជូនក្រុមប្រឹក្សាប្រជាជនខេត្ត ដើម្បីសម្រេចនូវខ្លឹមសារដែលមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំរដ្ឋបាលមូលដ្ឋាន និងការអនុវត្តដំណោះស្រាយរបស់ក្រុមប្រឹក្សាប្រជាជន។

២. រៀបចំរចនាសម្ព័ន្ធអង្គភាព ភារកិច្ច និងអំណាចជាក់លាក់របស់ស្ថាប័នជំនាញក្រោមគណៈកម្មាធិការប្រជាជនខេត្ត។

៣. រៀបចំ និងអនុវត្តថវិកាខេត្ត និងអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការអភិវឌ្ឍឧស្សាហកម្ម សំណង់ ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ កសិកម្ម រុក្ខាប្រមាញ់ នេសាទ ការដឹកជញ្ជូន និងប្រព័ន្ធធារាសាស្ត្រ រួមទាំងការអនុវត្តវិធានការគ្រប់គ្រង និងប្រើប្រាស់ដី ព្រៃឈើ ភ្នំ ទន្លេ បឹង ធនធានទឹក ធនធានរ៉ែ ធនធានក្នុងសមុទ្រ ដែនអាកាស និងធនធានធម្មជាតិផ្សេងៗទៀត ព្រមទាំងអនុវត្តវិធានការបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ និងការពារបរិស្ថានក្នុងខេត្ត។

៤. បង្កើត និងរៀបចំការអនុវត្តកម្មវិធីខេត្ត គម្រោង និងគម្រោងសម្រាប់តំបន់ និងតំបន់ជនជាតិភាគតិចដែលមានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមពិសេស។

៥. អនុវត្តវិធានការកសាងប៉ុស្តិ៍ការពារសន្តិសុខរបស់ប្រជាពលរដ្ឋក្នុងខេត្ត

៦. ធានានូវការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់ កសាងរដ្ឋាភិបាល និងព្រំដែនរដ្ឋបាល ការអប់រំ បណ្តុះបណ្តាល វិទ្យាសាស្ត្រ បច្ចេកវិទ្យា វប្បធម៌ និងព័ត៌មាន បណ្តុះបណ្តាលកាយសម្បទា កីឡា សុខភាព ការងារ គោលនយោបាយសង្គម ក្រុមជនជាតិភាគតិច សាសនា ការការពារជាតិ សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម។

៧. ធ្វើវិមជ្ឈការសិទ្ធិឱ្យគណៈកម្មាធិការប្រជាជនថ្នាក់ក្រោម។

**ក.៣. មុខងាររបស់រដ្ឋបាលខេត្ត**

ជារួម រដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការសម្របសម្រួលពិភាក្សា ការសម្រេចចិត្ត និងការកំណត់វិធានការចាំបាច់នានា ក្នុងគោលបំណងធានាការអនុវត្តតាមការណែនាំ និងសេចក្តីសម្រេចរបស់ស្ថាប័នថ្នាក់ជាតិ ដោយផ្អែកទៅតាមលក្ខខណ្ឌ/ស្ថានភាពជាក់លាក់ និងកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន ដែលក្នុងនោះមានមុខងារសំខាន់ៗចំនួន៧ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតយកចិត្តទុកដាក់ ដូចជា៖ ១)ការអភិវឌ្ឍសេដ្ឋកិច្ច ២)វប្បធម៌ និងការអប់រំ ៣)កិច្ចការសង្គម និងសន្តិសុខ ៤)បច្ចេកវិទ្យា និងបរិស្ថាន ៥)សាសនា និងកិច្ចការជនជាតិភាគតិច ៦)ការអនុវត្តច្បាប់ និង ៧)ការកែលម្អ និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក.៤. តួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត**

រដ្ឋបាលខេត្តមានតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម៖

១. រៀបចំ និងធានាការអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ទូទាំងខេត្ត

២. ដោះស្រាយបញ្ហានានានៅក្នុងខេត្ត ផ្អែកទៅតាមសិទ្ធិ និងអំណាចដែលផ្ទេរ

៣. អនុវត្តភារកិច្ច និងការទទួលខុសត្រូវដែលបានផ្ទេរដោយភ្នាក់ងារ/អង្គភាពថ្នាក់ជាតិ

៤. ត្រួតពិនិត្យ និងតាមដានការរៀបចំ និងប្រតិបត្តិការរបស់រដ្ឋបាលមូលដ្ឋានថ្នាក់ក្រោម (ក្រុង ស្រុក ឃុំ សង្កាត់) ក្នុងខេត្តរបស់ខ្លួន

៥. ទទួលខុសត្រូវចំពោះស្ថាប័នថ្នាក់ជាតិលើលទ្ធផលនៃការអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោម (ក្រុង ស្រុក ឃុំ សង្កាត់) នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

៦. សហការជាមួយស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលមូលដ្ឋានដទៃទៀតក្នុងការបង្កើនទំនាក់ទំនងសេដ្ឋកិច្ចរវាងតំបន់ និងអនុវត្តផែនការថ្នាក់តំបន់

៧. សម្រេច និងរៀបចំការអនុវត្តវិធានការនានា ដើម្បីលើកកម្ពស់ភាពម្ចាស់ការរបស់ប្រជាជន និងកៀរគរធនធានសង្គម ដើម្បីបម្រើដល់ការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ការការពារសន្តិសុខ

រចនាសម្ព័ន្ធនៃរដ្ឋបាលខេត្តនីមួយៗត្រូវមានការរៀបចំទៅតាមការណែនាំរបស់រដ្ឋបាលថ្នាក់ជាតិ ដោយអាចកែសម្រួលទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៅមូលដ្ឋាននីមួយៗ។ ជាក់ស្តែង រដ្ឋបាលខេត្តប៉ុញយឿង មានរចនាសម្ព័ន្ធដូចខាងក្រោម៖




### ក.៨. តួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក

រដ្ឋបាលក្រុង ស្រុកមានតួនាទី ការទទួលខុសត្រូវ ដូចខាងក្រោម៖

១. រៀបចំ និងធានាការអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់។

២. ធ្វើការសម្រេចចិត្តលើបញ្ហានានាទៅតាមមុខងារដែលបានផ្ទេរដូចមានចែងក្នុងច្បាប់។
៣. អនុវត្តភារកិច្ច និងការទទួលខុសត្រូវដែលបានផ្ទេរដោយរដ្ឋបាលថ្នាក់លើ។
៤. ត្រួតពិនិត្យ និងវាយតម្លៃការរៀបចំ និងប្រតិបត្តិការរបស់រដ្ឋបាលមូលដ្ឋានឃុំ សង្កាត់
៥. ទទួលខុសត្រូវចំពោះរដ្ឋបាលថ្នាក់ខេត្ត ចំពោះលទ្ធផលនៃការអនុវត្តភារកិច្ច និងអំណាចរបស់រដ្ឋបាលមូលដ្ឋាន(ឃុំ សង្កាត់) ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក
៦. សម្រេច និងរៀបចំការអនុវត្តវិធាននានា ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាជន និងគៀរគរធនធានសង្គមក្នុងការបម្រើដល់ការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការការពារជាតិ និងសន្តិសុខនៅទូទាំងទឹកដីនៃស្រុក។

រចនាសម្ព័ន្ធនៃរដ្ឋបាលក្រុងនីមួយៗត្រូវមានការរៀបចំទៅតាមការណែនាំរបស់រដ្ឋបាលថ្នាក់កណ្ដាល ដោយអាចកែសម្រួលទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៅមូលដ្ឋាននីមួយៗ។ ជាក់ស្តែងរដ្ឋបាលក្រុងធូយ៉ូវមោកនៃខេត្តប៊ិញយឿង មានរចនាសម្ព័ន្ធដូចខាងក្រោម៖




### ក.៦. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម៖
១. រៀបចំ និងធានាការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់។
២. ធ្វើការសម្រេចចិត្តលើបញ្ហានានាទៅតាមមុខងារដែលបានផ្ទេរដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងទៀត។
៣. អនុវត្តភារកិច្ច និងការទទួលខុសត្រូវដែលប្រគល់ដោយរដ្ឋបាលថ្នាក់លើ។
៤. ទទួលខុសត្រូវចំពោះរដ្ឋបាលថ្នាក់ស្រុកចំពោះលទ្ធផលនៃការអនុវត្តភារកិច្ចរបស់ខ្លួន។

៥. សម្រេច និងរៀបចំការអនុវត្តវិធានការនានា ដើម្បីលើកកម្ពស់ភាពជីវភាពរបស់ប្រជាជន និងកៀរគរធនធានសង្គមក្នុងការបម្រើដល់ការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងសន្តិសុខទូទាំងឃុំ សង្កាត់។

**៩. អំពីរដ្ឋបាលខេត្តប៊ិញយឿង**

ខេត្តប៊ិញយឿង គឺជាខេត្តមួយនៃប្រទេសវៀតណាមដែលស្ថិតនៅតំបន់ភាគអាគ្នេយ៍នៃប្រទេស និងជាតំបន់សេដ្ឋកិច្ចទី២ ដែលជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ។ ខេត្តនេះមានកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍខ្លាំងផ្នែកឧស្សាហកម្ម ដែលមានតំបន់**ឧស្សាហកម្មចំនួន ២៨កន្លែង** ដែលមានផ្ទៃដីសរុបជាង **១២,០០០ហិកតា** ក្នុងនោះមានសហគ្រាសក្នុងស្រុកចំនួន៣៦.៣៧៩ និងសហគ្រាសបរទេសចំនួន **៣.៥០៩** កំពុងដំណើរការសកម្មភាពរបស់ខ្លួន ជាមួយនឹងការវិនិយោគទុនសរុបជាង **៣២,២៣ន់លានដុល្លារអាមេរិក**។

ខេត្តប៊ិញយឿងមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តប៊ិញភឿក ខាងត្បូងជាប់នឹងទីក្រុងហូជីមិញ ខាងកើតជាប់នឹងខេត្តដុងណៃ និងខាងលិចជាប់នឹងទីក្រុងតាយណីង ដែលមានផ្ទៃក្រឡាចំនួន **២,៦៩៤.៤៣គ.ម²** (ស្មើ ០,៨៣%នៃប្រទេសវៀតណាម) និងមានប្រជាជនចំនួនប្រមាណ ៣លាននាក់ (ឆ្នាំ២០២៣)។ ខេត្តនេះមាន**រដ្ឋបាលក្រុងចំនួន០២ ស្រុកចំនួន០៧** ហើយក្រុង ស្រុកត្រូវបានបែងចែកទៅជា**សង្កាត់ចំនួន០៤ ឃុំចំនួន៤២** ដែលក្នុងចំណោមក្រុង ស្រុកទាំងនេះ ក្រុងធូយ៉ូវមោកគឺជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌ធំជាងគេ។

រដ្ឋបាលខេត្តប៊ិញយឿងអាចរកប្រាក់ចំណូលបានប្រមាណ **៣,០០០លានដុល្លារអាមេរិក**ក្នុងមួយឆ្នាំ ក្នុងនោះរដ្ឋបាលខេត្តបានផ្ទេរទៅឱ្យថ្នាក់ជាតិ **២,០០០លានដុល្លារអាមេរិក** និងបានចាត់ចែងសម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនចំនួន **១,០០០លានដុល្លារអាមេរិក**។ ប្រជាជនក្នុងខេត្តនេះមានប្រាក់ចំណូលជាមធ្យម (GDP per capital) ប្រមាណជា **៧,០០០ដុល្លារអាមេរិក**ក្នុងមួយឆ្នាំ (ឆ្នាំ ២០២៣)។



ការជួបពិភាក្សាជាថ្នាក់ដឹកនាំខេត្តប៊ិញយឿង



ការជួបពិភាក្សាជាថ្នាក់ដឹកនាំរដ្ឋបាលក្រុងធូយ៉ូវមោក




ទស្សនកិច្ចសិក្សានៅសាលាមត្តេយ្យសិក្សាឯកជន




ទស្សនកិច្ចសិក្សានៅសាលាមត្តេយ្យសិក្សាសាធារណៈ

### គ. ការរៀបចំប្រព័ន្ធអប់រំនៅប្រទេសវៀតណាម

**ប្រទេសវៀតណាម** បានរៀបចំរចនាសម្ព័ន្ធនៃការផ្តល់សេវាអប់រំ និងបណ្តុះបណ្តាល ដែលក្នុងនោះរួមមាន៖ ការអប់រំផ្លូវការ និងការអប់រំក្រៅប្រព័ន្ធ។ ការអប់រំផ្លូវការរួមបញ្ចូល ៣កម្រិតសំខាន់ៗដូចខាងក្រោម៖

- ✓ **ការអប់រំកុមារតូច៖**
  - ទារកដ្ឋាន (អាយុ ០៣ខែដល់ ០៣ឆ្នាំ) និង
  - មត្តេយ្យសិក្សា (អាយុ ៣-៥ឆ្នាំ)។
- ✓ **ការអប់រំចំណេះទូទៅ៖**
  - ការអប់រំបឋមសិក្សា មានរយៈពេល ០៥ឆ្នាំសិក្សា (ថ្នាក់ទី១ ដល់ថ្នាក់ទី៥)
  - ការអប់រំមធ្យមសិក្សាបឋមភូមិ មានរយៈពេល ០៤ឆ្នាំសិក្សា (ថ្នាក់ទី៦ ដល់ថ្នាក់ទី៩)
  - ការអប់រំមធ្យមសិក្សាទុតិយភូមិ រយៈពេល ០៣ឆ្នាំសិក្សា (ថ្នាក់ទី១០ ដល់ថ្នាក់ទី១២)។
- ✓ **កម្រិតឧត្តមសិក្សា៖**
  - បរិញ្ញាបត្ររង មានរយៈពេល ០២ឆ្នាំ
  - បរិញ្ញាបត្រ មានរយៈពេល ០៤ឆ្នាំ
  - អនុបណ្ឌិត មានរយៈពេលពី ០១ឆ្នាំទៅ ០២ឆ្នាំសិក្សា
  - បណ្ឌិត មានរយៈពេលពី ០២ឆ្នាំទៅ ០៣ឆ្នាំសិក្សា។

ក្រៅពីសេវាអប់រំផ្លូវការ រដ្ឋាភិបាលវៀតណាមក៏រៀបចំឱ្យមានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ការអប់រំក្រៅប្រព័ន្ធ) ដែលផ្តោតលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កម្មវិធីអក្ខរកម្ម និងជំនាញបច្ចេកទេសសម្រាប់ប្រជាពលរដ្ឋដែលមិនអាចបន្តការសិក្សាក្នុងប្រព័ន្ធ។

សាលារៀននៅក្នុងប្រព័ន្ធអប់រំវៀតណាមត្រូវបានរៀបចំតាមប្រភេទដូចខាងក្រោម៖

- ✓ សាលាសាធារណៈដែលត្រូវបានបង្កើតឡើង និងផ្តល់ថវិកាចំណាយដោយរដ្ឋ
- ✓ សាលាដែលបង្កើតឡើងដោយសហគមន៍ ដែលត្រូវបានបង្កើតឡើង និងផ្តល់មូលនិធិប្រតិបត្តិការដោយសហគមន៍មូលដ្ឋាននីមួយៗ
- ✓ សាលាឯកជន ដែលត្រូវបានបង្កើតឡើងដោយវិស័យឯកជន។

**ឃ. ការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសវៀតណាម**

ផ្អែកតាមការសិក្សាស្រាវជ្រាវលើឯកសារពាក់ព័ន្ធនានា និងការជួបពិភាក្សាផ្ទាល់ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធនៃរដ្ឋបាលក្រុងធូយ៉ូវម៉ុក និងរដ្ឋបាលខេត្តប៊ិញយឿង ព្រមទាំងការទស្សនកិច្ចនៅតាមសាលារៀនមួយចំនួន ក្រុមការងារបានសិក្សា និងស្វែងយល់អំពីការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅថ្នាក់ក្រោមជាតិនៅប្រទេសវៀតណាម ដូចខាងក្រោម៖

– **ក្រសួងអប់រំ និងបណ្តុះបណ្តាល** ទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយអប់រំ កម្មវិធីសិក្សាសម្រាប់កុមារតូច និងការអប់រំចំណេះទូទៅ ការកំណត់ស្តង់ដា និយាម សៀវភៅសិក្សា និងសម្ភារបង្រៀន ផែនការថវិកា និងការធានាគុណភាពអប់រំ

– **រដ្ឋបាលខេត្ត** ដែលមានមន្ទីរអប់រំ និងបណ្តុះបណ្តាលជាសេនាធិការ ទទួលខុសត្រូវលើការគ្រប់គ្រង និងការផ្តល់សេវាអប់រំមធ្យមសិក្សាទុតិយភូមិ ថ្នាក់វិទ្យាល័យ (ថ្នាក់ទី១០ ដល់ទី១២) និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

– **រដ្ឋបាលក្រុង ស្រុក** ដែលមានការិយាល័យអប់រំ និងបណ្តុះបណ្តាលជាសេនាធិការ ទទួលខុសត្រូវលើការគ្រប់គ្រង និងការផ្តល់សេវាការអប់រំកុមារតូច (អាយុ ០៣ខែ ដល់ ០៥ខែ) ការអប់រំបឋមសិក្សា (ថ្នាក់ទី១ ដល់ថ្នាក់ទី៥) និងការអប់រំមធ្យមសិក្សាបឋមភូមិថ្នាក់អនុវិទ្យាល័យ (ទី៦ ដល់ទី៩)។

**ឃ.១. ការរៀបចំកម្មវិធីសិក្សា**

ក្រសួងអប់រំ និងបណ្តុះបណ្តាលនៅថ្នាក់ជាតិជាស្ថាប័នទទួលខុសត្រូវក្នុងការរៀបចំ និងដាក់ចេញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលសម្រាប់ការអប់រំចាប់ពីកុមារតូចរហូតដល់ចំណេះទូទៅទូទាំងប្រទេស។ ផ្អែកលើកម្មវិធីសិក្សាដែលបានដាក់ចេញដោយថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានមន្ទីរអប់រំជាសេនាធិការ អាចកែសម្រួលកម្មវិធីសិក្សាសម្រាប់សាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកទៅលើតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ ដូចជាការបញ្ចូលជំនាញភាសាបរទេស សិល្បៈ ឬមុខវិជ្ជាទាំងឡាយណាដែលជាតម្រូវការទីផ្សារការងារ។ ការកែសម្រួលកម្មវិធីសិក្សានេះត្រូវស្ថិតក្នុងក្របខណ្ឌអប្បបរិមាដែលកំណត់ដោយក្រសួងអប់រំ។

**ឃ.២. ការជ្រើសរើសគ្រូបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀន**

រដ្ឋបាលខេត្តជាស្ថាប័នដែលទទួលខុសត្រូវក្នុងការជ្រើសរើសគ្រូបង្រៀនទាំងនៅកម្រិតអប់រំកុមារតូច បឋមសិក្សា និងអប់រំចំណេះទូទៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលខេត្តអាចធ្វើប្រតិភូកម្មសិទ្ធអំណាចនៃការជ្រើសរើសគ្រូបង្រៀនទៅឱ្យរដ្ឋបាលក្រុង ស្រុក (ឧទាហរណ៍៖ រដ្ឋបាលខេត្តប៊ិញយឿងបានធ្វើប្រតិភូកម្មការទទួលខុសត្រូវក្នុងការជ្រើសរើសគ្រូបង្រៀនទៅឱ្យរដ្ឋបាលក្រុងធូយ៉ូវម៉ុក)។

បន្ទាប់ពីឆ្លងកាត់ការប្រឡងជ្រើសរើស បេក្ខជនជាគ្រូបង្រៀនដែលត្រូវជ្រើសរើសទាំងនោះត្រូវបញ្ជូនទៅទទួលការបណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ និងបណ្តុះបណ្តាល។ គ្រូបង្រៀននៅប្រទេសវៀតណាមត្រូវបានសង្គមគោរពយ៉ាងខ្លាំង និងជាមុខតំណែងដ៏មានកិត្យានុភាព។

**ឃ.៣. យន្តការគ្រប់គ្រងសាលា**

សាលារៀននីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយត្រូវគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ និងបណ្តុះបណ្តាល និងត្រូវរៀបចំយន្តការដឹកនាំ រួមមានក្រុមប្រឹក្សាសាលា នាយកសាលា ក្រុមប្រឹក្សាភិបាល អង្គការបក្សប្រចាំនៅសាលា និងអង្គការមហាជននិងសង្គមនៅតាមសាលារៀន។

**ឃ.៤. ការតែងតាំងនាយកសាលា**

នាយកសាលាមត្តេយ្យសិក្សា នាយកសាលាបឋមសិក្សា និងនាយកសាលាអនុវិទ្យាល័យ គឺត្រូវបានតែងតាំងដោយរដ្ឋបាលក្រុង ស្រុក។ នាយកសាលាវិទ្យាល័យត្រូវបានតែងតាំងដោយរដ្ឋបាលខេត្ត ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលក្រុង ស្រុក។

**ឃ.៥. ការរៀបចំកម្មវិធីអាហារថ្ងៃត្រង់សម្រាប់ការអប់រំកុមារតូច**

ការអប់រំកុមារតូចនៅវៀតណាមធ្វើឡើងក្នុងរយៈពេលមួយថ្ងៃ (៨ម៉ោង) ហើយសាលាផ្តល់អាហារថ្ងៃត្រង់ដល់កុមារដែលបានចូលរៀន ដោយមានបដិភាគថវិកាចំនួនប្រមាណ**៤០ដុល្លារ**ពីអាណាព្យាបាលសម្រាប់ថ្លៃអាហារថ្ងៃត្រង់ ប៉ុន្តែការចូលបដិភាគថវិកានេះត្រូវបានលើកលែងសម្រាប់សិស្សក្រីក្រ។

**ឃ.៦. ការកំណត់កញ្ចប់ថវិកាវិស័យអប់រំនៅមូលដ្ឋាន និងការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានលើកទឹកចិត្តឱ្យកំណត់ទំហំថវិកាសម្រាប់វិស័យអប់រំចំនួន២៥% នៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។ រដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធចាប់ពីការអប់រំកុមារតូច រហូតដល់វិទ្យាល័យដោយប្រើប្រាស់កញ្ចប់ថវិការបស់ខ្លួន។

**ឃ.៧. យន្តការគាំទ្រ និងតាមដាន ត្រួតពិនិត្យ**

រដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវពេញលេញក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំ រួមទាំងការគាំទ្រទាំងផ្នែកបច្ចេកទេស ថវិកា និងសម្ភារនានាដល់សាលារៀនដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសាលារៀន តាមរយៈមន្ទីរ/ការិយាល័យអប់រំ និងបណ្តុះបណ្តាល។

**ឃ.៨. ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាព**

រដ្ឋបាលក្រុង ស្រុកដែលទទួលខុសត្រូវលើការគ្រប់គ្រងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងអនុវិទ្យាល័យ ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះរដ្ឋបាលខេត្ត ហើយរដ្ឋបាល

ខេត្តត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវលើការផ្តល់សេវាអប់រំទាំងមូលចំពោះក្រសួង ស្ថាប័នថ្នាក់ជាតិ រួមទាំងការទទួលខុសត្រូវលើការផ្តល់សេវាអប់រំរបស់រដ្ឋបាលក្រុង ស្រុកផងដែរ ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តអាចធ្វើប្រតិភូកម្មកិច្ចការជាក់លាក់ណាមួយពាក់ព័ន្ធនឹងការអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដូចជាការជ្រើសរើសគ្រូ និងការសាងសង់ជួសជុលជាដើម។

## III. មេរៀន បទពិសោធន៍ល្អៗនៃការអនុវត្តមុខងារអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រទេសវៀតណាម

ផ្អែកលើការសិក្សាស្រាវជ្រាវ និងលទ្ធផលនៃការជួបពិភាក្សាជាមួយថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង មន្ទីរពាក់ព័ន្ធ និងលោកគ្រូ អ្នកគ្រូ ព្រមទាំងការទស្សនកិច្ចផ្ទាល់នៅសាលារៀន គណៈប្រតិភូកម្ពុជាបានធ្វើការកត់សម្គាល់ និងដកស្រង់បាននូវមេរៀន និងបទពិសោធន៍ល្អៗពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅថ្នាក់ក្រោមជាតិនៃប្រទេសវៀតណាម ដែលអាចជាមូលដ្ឋានក្នុងការឆ្លុះបញ្ចាំង និងពិចារណាសម្រាប់ការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរមុខងារអប់រំនៅកម្ពុជាក្នុងនោះរួមមាន៖

- ប្រព័ន្ធអប់រំមូលដ្ឋានចាប់ពីការអប់រំកុមារតូចរហូតដល់ចំណេះទូទៅ (មត្តេយ្យសិក្សាដល់វិទ្យាល័យ) ត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងស្រុងទៅតាមប្រភេទរដ្ឋបាលនីមួយៗ ដោយផ្អែកទៅតាមសមត្ថភាពនៃថ្នាក់រដ្ឋបាលនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានអង្គភាពផ្ទាល់របស់ខ្លួនទទួលខុសត្រូវលើការងារអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដូចជាមន្ទីរអប់រំស្ថិតក្រោមឱវាទរបស់រដ្ឋបាលខេត្ត និងការិយាល័យអប់រំក្រោមឱវាទរបស់រដ្ឋបាលក្រុង ស្រុក។ ប្រការនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមយ៉ាងសកម្ម និងទទួលខុសត្រូវពេញលេញក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំ
- រដ្ឋបាលថ្នាក់ក្រោមជាតិវៀតណាមទទួលបានសិទ្ធិ និងការទទួលខុសត្រូវពេញលេញក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំនៅមូលដ្ឋាន ចាប់តាំងពីការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាល ការតែងតាំងរហូតដល់ចូលនិវត្តន៍ ព្រមទាំងការសាងសង់ ការជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន
- រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចមានភាពបត់បែនក្នុងការគ្រប់គ្រង និងផ្តល់សេវាអប់រំនៅមូលដ្ឋាននីមួយៗទៅតាមស្ថានភាពភូមិសាស្ត្រ និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ដូចជាការរៀបចំកម្មវិធីសិក្សា ការជ្រើសរើសគ្រូជាដើម) ហើយក្រសួងអប់រំ និងបណ្តុះបណ្តាល មានតួនាទីក្នុងការរៀបចំគោលនយោបាយ ស្តង់ដា និយាម និងកម្មវិធីសិក្សា
- រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានទាំងធនធានហិរញ្ញវត្ថុដែលផ្ទេរពីថ្នាក់ជាតិ និងប្រភពចំណូលពីមូលដ្ឋានរបស់ខ្លួនគ្រប់គ្រាន់យ៉ាងតិច២៥% នៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ សម្រាប់ការងារវិស័យអប់រំ ព្រមទាំងការចូលរួមពីសហគមន៍សម្រាប់ការអភិវឌ្ឍវិស័យអប់រំនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់
- រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិសម្រេចអំពីយន្តការលើកទឹកចិត្តដល់វិស័យឯកជនក្នុងការបើកដំណើរការសាលារៀនឯកជននៅក្នុងមូលដ្ឋានរបស់ខ្លួន ដូចជាការលើកលែងពន្ធលើប្រាក់ចំណូល ការបន្ធូរបន្ថយអត្រាពន្ធ និងការផ្តល់ទីតាំងជួលក្នុងតម្លៃទាបជាដើម ដែលប្រការនេះបានជំរុញ និងលើក

ទឹកចិត្តឱ្យវិស័យឯកជនចូលរួមក្នុងការវិនិយោគលើវិស័យអប់រំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– រដ្ឋបាលថ្នាក់ខេត្ត គឺជាសេនាធិការរបស់ថ្នាក់ជាតិដែលទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងគាំទ្រទៅដល់រដ្ឋបាលក្រុង ស្រុកលើការគ្រប់គ្រង និងផ្តល់សេវាអប់រំទៅតាមច្បាប់កំណត់

– សាលាមត្តេយ្យសិក្សាសាធារណៈនៅប្រទេសវៀតណាម បានរៀបចំកម្មវិធីបង្រៀនសិស្សពេញមួយថ្ងៃ។ ការរៀបចំបែបនេះបានកសាងមូលដ្ឋានគ្រឹះចំណេះដឹង (ឥរិយាបថ សីលធម៌ ការចូលរួមក្នុងសង្គម) ដ៏រឹងមាំសម្រាប់កុមារម្នាក់ៗសម្រាប់ត្រៀមបន្តថ្នាក់បឋមសិក្សា។ ទន្ទឹមនេះ សាលារៀនមត្តេយ្យសិក្សាអាចកៀរគរការចូលរួមពីសហគមន៍ក្នុងការបំពេញភាពខ្វះចន្លោះរបស់សាលារៀន តាមរយៈការចូល រួមបដិភាគថវិកាសម្រាប់អាហារថ្ងៃត្រង់របស់កុមារ

– សាលាមត្តេយ្យសិក្សានៅវៀតណាមរៀបចំបានស្អាត បរិស្ថានល្អ និងមានទីធ្លាធំទូលាយ បំពាក់ដោយឧបករណ៍ សម្ភារបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់ការរៀន និងបង្រៀន ដូចជាតន្ត្រី កីឡា កសិកម្ម និងគំនូសសញ្ញាចរាចរណ៍ជាដើម

– គ្រឹះស្ថានសិក្សានីមួយៗទទួលបានការគាំទ្រ និងត្រួតពិនិត្យជាប្រចាំពីរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធានាដល់គុណភាពសេវាអប់រំនៅមូលដ្ឋានរបស់ខ្លួន

ជារួម រដ្ឋបាលថ្នាក់ជាតិមានតួនាទីរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានបច្ចេកទេស ការគាំទ្រ និងការតាមដានត្រួតពិនិត្យលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិគឺជារដ្ឋបាលឯកភាពមានសិទ្ធអំណាចពេញលេញក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តផ្ទាល់លើគ្រប់វិស័យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងមានសិទ្ធអំណាចពេញលេញក្នុងការគ្រប់គ្រងចំណូលចំណាយ និងការចាត់ចែងថវិការបស់ខ្លួនទៀតផង។

## IV. កម្មវិធីផ្សេងៗ

ក្រៅពីការជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត និងក្រុង និងការទស្សនកិច្ចនៅគ្រឹះស្ថានសិក្សាមួយចំនួន គណៈប្រតិភូកម្ពុជាក៏បានទស្សនកិច្ចនៅសកលវិទ្យាល័យ Eastern Interna-tional University (EIU) ក្រុមហ៊ុនថាកូ និងក្រុមហ៊ុនចំការកៅស៊ូដូវទៀង។ ជាការកត់សម្គាល់ ក្រុមហ៊ុនថាកូ និងក្រុមហ៊ុនចំការកៅស៊ូដូវទៀងមានកិច្ចសហការយ៉ាងល្អប្រសើរជាមួយរដ្ឋបាលខេត្តក្រចេះ ដែលក្រុមហ៊ុនទាំងពីរនេះបានមកវិនិយោគវិស័យកសិឧស្សាហកម្មនៅកម្ពុជា ដែលក្នុងនោះក្រុមហ៊ុនថាកូបានវិនិយោគលើការចិញ្ចឹមគោ ការដាំចេក និងកៅស៊ូលើផ្ទៃដីសរុប ១០,០០០ហិកតានៅស្រុកស្នួល ខេត្តក្រចេះ។ ក្នុងការជួបពិភាក្សានេះ ក្រុមហ៊ុនទាំងពីរបានថ្លែងនូវអំណរគុណដល់រដ្ឋបាលខេត្តក្រចេះដែលតែងតែផ្តល់កិច្ចសហការ និងគាំទ្រដល់ដំណើរការវិនិយោគរបស់ក្រុមហ៊ុន ហើយក្រុមហ៊ុនមានគម្រោងពង្រីកការវិនិយោគជាជំហានៗបន្ថែមទៀតនៅកម្ពុជា។ បន្ថែមពីនេះ សកលវិទ្យាល័យ EIU ក៏បានសម្រេចផ្តល់អាហារូបករណ៍ចំនួន ១០កន្លែង ដល់សិស្សានុសិស្សនៅខេត្តក្រចេះ ចាប់ពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៦ ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ។




ទស្សនកិច្ចសិក្សានៅក្រុមហ៊ុនចម្ការកៅស៊ូដូវទៀង




ទស្សនកិច្ចសិក្សានៅក្រុមហ៊ុនថាកូ




ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងខេត្តក្រចេះ និងខេត្តប៊ិញយឿង
អំពីការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រដល់រដ្ឋបាលខេត្តក្រចេះ (២០២៤-២០២៦)

## V. សេចក្តីសន្និដ្ឋាន

ជារួម ទស្សនកិច្ចសិក្សាទៅកាន់ខេត្តប៊ិញយឿងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយលទ្ធផលយ៉ាងល្អប្រសើរទៅតាមកម្មវិធី និងគោលបំណងដែលគ្រោងទុក។ ទស្សនកិច្ចសិក្សានេះបានបង្កឱកាសឱ្យថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសសំខាន់ៗនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃដែលជាតួអង្គសំខាន់ក្នុងការចូលរួមរៀបចំតាក់តែងគោលនយោបាយវិមជ្ឈការវិស័យអប់រំ អាចសិក្សាស្វែងយល់ និងប្រមូលបាននូវមេរៀន និងបទពិសោធន៍ល្អៗពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាអប់រំគ្រប់កម្រិតនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការជួបពិភាក្សា និងទស្សនកិច្ចនៅគ្រឹះស្ថានសិក្សាមួយចំនួនដោយផ្ទាល់។ មេរៀន និងបទពិសោធន៍ល្អៗទាំងនេះនឹងរួមចំណែកក្នុងការកែលម្អការផ្តល់សេវាអប់រំនៅកម្ពុជាឱ្យកាន់តែល្អប្រសើរឡើងតាមរយៈការឆ្លុះបញ្ចាំងស្ថានភាពនៃប្រទេសកម្ពុជាផង និងការអនុវត្តនៅប្រទេសផ្សេងៗក្នុងតំបន់ផង។

ផ្អែកលើការសិក្សាស្រាវជ្រាវ និងមេរៀន បទពិសោធន៍នានាដែលបានសិក្សាទាំងនៅប្រទេសវៀតណាម និងក្នុងតំបន់ យើងអាចចាត់ទុកបានថា ការធ្វើកំណែទម្រង់វិមជ្ឈការវិស័យអប់រំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការលើកកម្ពស់គុណភាពនៃការផ្តល់សេវាអប់រំនៅថ្នាក់ក្រោមជាតិ ជាពិសេសការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាអប់រំនៅមូលដ្ឋាន ប្រកបដោយភាពបត់បែនទៅតាមតម្រូវការ និងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។ ទន្ទឹមនឹងនេះ ដើម្បីធានាបានភាពជោគជ័យនៃការអនុវត្តកំណែទម្រង់វិមជ្ឈការវិស័យអប់រំនេះ ក៏ចាំបាច់ត្រូវមានការចូលរួមគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិពីគ្រប់ភាគីពាក់ព័ន្ធ ការផ្ទេរធនធានសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារ ការតាមដាននិងត្រួតពិនិត្យ និងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្តល់ការណែនាំបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ៕

ថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

**អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. និងជា**

**ប្រធានគណៈប្រតិភូកម្ពុជា**

លេខាធិការដ្ឋាន

**ចាន់ សុធា**